**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ដឺ សូលហ្គៀ ខេមបូឌា ឯ.ក
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក សហជីព និងប្រធានក្រុម ប្រធានផ្នែក ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង០០នាទី ព្រឹក នៅក្នុងរោងចក្រ ដឺ សូលហ្គៀ ខេមបូឌា ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន នឹងតំណាងកម្មករ និយោជិត សហជីព និង ប្រធានក្រុម ប្រធានផ្នែក នៅក្នុងអង្គប្រជុំនេះ តំណាងនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ១៧៣ នាក់(ស្រី ១៣៨នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៣៦៣នាក់(ស្រី ២៦២ នាក់)រយៈ ពេល ១៤ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២៣ ។ ហើយក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ  កម្មករ  និយោជិតម្នាក់ៗបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម្ភចំនួន ១៥ដុល្លារសហរដ្ឋអាមេរិក គិតពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ដែលត្រូវបើកជូននៅ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

អង្គប្រជុំបានចប់នៅវេលាម៉ោង១០ និង ០០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃសុក្រ ៨រោជ ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
កណ្តាល ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣

**តំណាងនាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ដឺ សូល ហ្គៀ (ខេមបូឌា) ឯ.ក THE SOUL GEAR (CAMBODIA) CO.,LTD. KINGDOM OF CAMBODIA

**គី សីហា**

## ស្នាមមេដៃតំណាងកម្មករ និយោជិត
## កិច្ចពមព្រៀង
## រវាង
## ក្រុមហ៊ុន ដឺ សូលហ្គៀ ខេមបូឌា ឯ.ក
## ជាមួយតំណាងកម្មករ ប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រធានផ្នែក ប្រចាំក្រុមហ៊ុន

១. នុត ណុល    ២.នៅ ណារី    ៣. សមប៊ុន មេសា    ៤. សាត់ ចន្ថា

៥. គី ស្រីណាន